






មន្ត្រីអង្គការសង្គមស៊ីវិលផ្តល់បទសម្ភាសដល់អ្នកសារព័ត៌មានកាលពីថ្ងៃម្សិលមិញ។ P ផា លីណា

# សង្គមស៊ីវិលចាត់ទុកកិច្ចសហការដោះស្រាយជម្លោះដីធ្លីនៅរដ្ឋសភា គឺជាការបើកទំព័រប្រវត្តិសាស្ត្រថ្មី

Recommend Share 14 g+1 0 Tweet 0 M Email

**ភ្នំពេញៈ** មន្ត្រីអង្គការសង្គមស៊ីវិលបានចាត់ទុកជំនួបជាមួយគណៈកម្មការ ទី១ នៃរដ្ឋសភា ក្នុងការសហការស្វែងរកដំណោះស្រាយរឿងវិវាទដីធ្លីនៅ ភូមិឡពាង ខេត្តកំពង់ឆ្នាំង ថា ជាការបើកទំព័រប្រវត្តិសាស្ត្រលើកដំបូងថ្មីមួយ ដែលបង្ហាញពីក្តីសង្ឃឹមថា បញ្ហាជម្លោះដីធ្លីដែលបានកើតឡើងនៅក្នុង ប្រទេសកម្ពុជា នឹងមានការដោះស្រាយជាបន្តបន្ទាប់។

សមាជិកគណៈកម្មការ ទី១ នៃរដ្ឋសភា ផ្នែកសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងអង្កេតនឹងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា បានបើកកិច្ចប្រជុំពិភាក្សាជាមួយមន្ត្រីអង្គការសិទ្ធិមនុស្សលីកាដូ និងសមាគមការពារសិទ្ធិមនុស្សអាដហុក នៅវិមានរដ្ឋសភា កាលពីម្សិលមិញ ដើម្បីពិភាក្សារកដំណោះស្រាយបញ្ចប់វិវាទដីធ្លីរវាងសហគមន៍ ឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាមួយក្រុមហ៊ុន ខេឌីស៊ី របស់លោកស្រី ជា ខេង ភរិយាលោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ដែលបានអូសបន្លាយជិត ១០ ឆ្នាំមកហើយនោះ។

បន្ទាប់ពីកិច្ចប្រជុំពិភាក្សា លោក នី ចរិយា ប្រធានផ្នែកស៊ើបអង្កេតសិទ្ធិមនុស្សនិងច្បាប់នៃសមាគមអាដហុក បានមានប្រសាសន៍ថា អង្គការសង្គមស៊ីវិលទាំងពីរ បានដាក់នូវឯកសារមួយចំនួនពាក់ព័ន្ធនឹងករណីដីធ្លីនេះ ទៅកាន់គណៈកម្មការ ទី១ រដ្ឋសភា ដើម្បីពិនិត្យនិងចាត់វិធានការដោះស្រាយ។ លោកបានបន្តថា៖ «យើងទាំងអស់គ្នាបានមូលមាត់គ្នារកដំណោះស្រាយ និងយុត្តិធម៌ជូនប្រជាជនកុំឲ្យគាត់ស្រក់ទឹកភ្នែកទៀត ហើយយើងក៏មិនធ្វើឲ្យមានអំពើអយុត្តិធម៌ចំពោះក្រុមហ៊ុនដែរ»។

លោក នី ចរិយា បានបន្តថា នេះជាប្រវត្តិសាស្ត្រហើយ ដែលរដ្ឋសភាបានសហការជាមួយអង្គការសង្គមស៊ីវិល ក្នុងការរកដំណោះស្រាយរឿងដីធ្លីជម្លោះដីធ្លីនៅ ឡពាង នេះហើយលោកសង្ឃឹមថានឹងមានការសហការបែបនេះជាបន្តបន្ទាប់ទៀតដើម្បីដោះស្រាយបញ្ហាដីធ្លីនៅតំបន់ផ្សេងៗទៀត។

ចំណែកលោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេតនៃអង្គការលីកាដូ បានបន្ថែមថា ពួកគាត់ក៏បានស្នើឲ្យគណៈកម្មការនេះ ជួយអន្តរាគមន៍ឲ្យមានការដោះលែងប្រជាពលរដ្ឋដែលកំពុងជាប់ឃុំដោយសារជម្លោះដីធ្លីផងដែរ ដើម្បីឲ្យពួកគាត់ចេញមកតតាំងដោះស្រាយជាមួយគ្នាដោយយុត្តិធម៌។

លោកបានបញ្ជាក់ថា៖ «បើតំណាងរបស់គាត់នៅក្នុងពន្ធនាគារ នោះការដោះស្រាយក៏មិនងាយ

## ព័ត៌មានពាក់ព័ន្ធ

- គណៈកម្មការ ទី១ សភាប្រជុំនឹងអង្គការពីររឿងជម្លោះអ្នក ភូមិឡពាង
- ពលរដ្ឋបាត់ដីសុំទូតអាមេរិកជួយអន្តរាគមន៍
- ជម្លោះដីឡពាងបណ្តាលឲ្យក្មេងៗបាត់ឱកាសសិក្សា
- គណៈកម្មការ ទី១ នៃរដ្ឋសភាសន្យាដោះជម្លោះដីឲ្យពលរដ្ឋ
- រដ្ឋាភិបាលអសមត្ថភាពក្នុងការដោះស្រាយជម្លោះដីធ្លី
- កម្មករក្រុមហ៊ុន ខេឌីស៊ី ស្នើសុំកុំឲ្យដោះលែងអ្នកភូមិឡពាង
- ពលរដ្ឋដែលមានជម្លោះដីធ្លីផ្ទុះការតវ៉ាដើម្បីស្វែងរកដំណោះស្រាយ
- ជម្លោះដីធ្លីបានកក្រើកឡើងច្រើនជាងឆ្នាំមុន

## វីឌីអូថ្មីបំផុត



### កិច្ចសម្ភាសន៍រវាងអ្នកយកព័ត៌មានទូរទស្សន៍ ស៊ីអិនស៊ី និងនិពន្ធនាយកកាសែតភ្នំពេញប៉ុស្តិ៍

ហក កែ គឹមសុង និពន្ធនាយកកាសែត ភ្នំពេញ ប៉ុស្តិ៍ និងកាសែតកម្ពុជាចុងសប្តាហ៍ បានផ្តល់បទសម្ភាសន៍ជូនលោក ប្រាក់ សម្ផស្ស ផលិតករព័ត៌មាន ក្នុងកម្មវិធីចក្ខុវិស័យកម្ពុជា នៃប៉ុស្តិ៍ទូរទ



### លោក ឈាង វុន ថា៖ ការស្រុះស្រួលនយោបាយត្រូវបញ្ចប់

លោកស្រីមូរ សុខហួរ និង លោក យឹម សុវណ្ណ បានបាត់បង់ឱកាសជាប្រធានគណៈកម្មាធិការទី៨ និងទី១០ នៃរដ្ឋសភាជាតិ។ ទោះជាយ៉ាងណា តំណែងប្រធានគណៈកម្មាធិការទាំងពីរនេះ ដែលជ្រើសរើសកាលពីម្សិលមិញ ត្រូវបានលោក






ដែរ។ យើងបានស្នើហើយ ហើយយើងនឹងជូនព័ត៌មាននូវករណីដីធ្លីដែលពាក់ព័ន្ធនឹងការចាប់តំណាងដាក់ពន្ធនាគារនេះ ដាក់ជូនរដ្ឋសភាជាបន្តបន្ទាប់ទៀត»។

របាយការណ៍របស់សមាគមអាដហុក បានចេញផ្សាយកាលពីថ្ងៃ ទី១៩ ខែសីហា ថា រយៈពេល ៧ ខែ ដើម ឆ្នាំ២០១៤ នេះមានពលរដ្ឋចំនួន ១៩នាក់ ត្រូវបានចាប់ខ្លួននិងឃុំខ្លួននៅពន្ធនាគារ ខណៈ ឆ្នាំ២០១៣ មានចំនួន ៤៣ នាក់។

លោក អេង ឆៃអ៊ាង ប្រធានគណៈកម្មការ ទី១ នៃរដ្ឋសភា បានមានប្រសាសន៍ថា ការជួបពិភាក្សានឹងប្រឹក្សាយោបល់ជាមួយភាគីអង្គការសង្គមស៊ីវិល និងភាគីនៃជម្លោះនោះ គឺជាជំហានថ្មីមួយធ្វើឡើងបន្ទាប់ពីបានទទួលបណ្ដឹងរបស់ប្រជាពលរដ្ឋ ហើយគណៈកម្មការនឹងចូលរួមដោះស្រាយសម្របសម្រួលធ្វើយ៉ាងណាឲ្យភាគីទាំងពីរទទួលបានយុត្តិធម៌ក្នុងរឿងជម្លោះដីធ្លីនេះ។

លោកបានបញ្ជាក់ថា៖ «ក្រៅពីបានជួបអង្គការសង្គមស៊ីវិល យើងជួបជាមួយតំណាងក្រុមហ៊ុន និងភាគីដែលពាក់ព័ន្ធ។ យើងមិនទាន់ដឹងថា ដំណោះស្រាយយ៉ាងណានៅឡើយទេ ប៉ុន្តែយើងខិតខំធ្វើយ៉ាងម៉េចដោះស្រាយឲ្យបានឆាប់»។

ការស្វែងរកដំណោះស្រាយនេះ បានធ្វើឡើងខណៈដែលអ្នក ភូមិឡពាង និងអ្នកភូមិ ៣ ផ្សេងទៀតប្រមាណ ៦០នាក់ តំណាងឲ្យអ្នកភូមិ ៨២ គ្រួសារដែលមានជម្លោះដីធ្លីជាមួយក្រុមហ៊ុន ខេឌីស៊ី ដែលបានមកស្នាក់នៅរាជធានីភ្នំពេញ ជាងកន្លះខែហើយ ដើម្បីដាក់ញត្តិស្វែងរកអន្តរាគមន៍នៅខុទ្ទកាល័យលោកនាយករដ្ឋមន្ត្រី និងនៅតាមស្ថាប័ននានាមួយចំនួនទៀត។

កាលពីម្សិលមិញនេះដែរ អ្នកតំណាងពលរដ្ឋនៅ ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ និងតំណាងពលរដ្ឋនៅ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលបានឡើងមកស្នាក់នៅក្នុងវត្តចាស់ និង វត្តសាមគ្គីរង្សី ក្នុងរាជធានីភ្នំពេញ ក៏បានទៅដាក់ញត្តិសុំអន្តរាគមន៍ករណីវិវាទដីធ្លីរបស់ពួកគាត់ នៅរដ្ឋសភាផងដែរ។

លោក តុល ប្រាសាទ ជំនួយការលេខាធិការគណៈកម្មការ ទី១ រដ្ឋសភា បានចេញមកទទួលញត្តិរបស់ប្រជាពលរដ្ឋ ហើយថា នឹងបញ្ជូនញត្តិនេះទៅគណៈកម្មការដោះស្រាយវិវាទធ្វើការពិនិត្យ និងចាត់ការទៅតាមនីតិវិធីច្បាប់៕

Contact author: ប៊ិច សុធារី

0 Comments

Please, login or register to post a comment

The Phnom Penh Post

ភ្នំពេញ ប៉ុស្ដិ៍

Post Media Co Ltd
888 Building F, 8th Floor, Phnom Penh Center
Corner Sothearos & Sihanoulk Blvd
Sangkat Tonle Bassac
12301 Phnom Penh
Cambodia

Tel: +855(0) 23 214 3 11-17
Fax: +855(0) 23 214 318

Company

Staff list

Sections

ព័ត៌មានជាតិ

Facebook Twitter Google +

SEVENDAYS

LIFT THE ESSENTIAL MAGAZINE FOR CAMBODIAN YOUTH.

Copyright © 2013 The Phnom Penh Post. All Rights Reserved. Web design by IConsulting